01204615

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/date de reception): 18 / 02 / 2016
ម៉ោង (Time/Heure) : 15:50
មន្ត្រីទទួលបន្ទុកសំណុំរឿង /Case File Officer/L'agent chargé du dossier: SANN RADA

E364/1

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

---

## អង្គជំនុំជម្រះសាលាដំបូង

ថ្ងៃទី ១៨ ខែ កុម្ភៈ ឆ្នាំ ២០១៦

**ជូនចំពោះ៖** **គ្រប់ភាគីទាំងអស់នៃសំណុំរឿង ០០២**

**ពី៖** **ចៅក្រម និល ណុន ប្រធានអង្គជំនុំជម្រះសាលាដំបូង**

**ចម្លងជូន៖** **លោក/លោកស្រីចៅក្រម និងមន្ត្រីច្បាប់ជាន់ខ្ពស់នៃអង្គជំនុំជម្រះសាលាដំបូង**

**កម្មវត្ថុ៖** **សេចក្តីសម្រេចលើសេចក្តីជំទាស់របស់មេធាវីការពារក្តី ខៀវ សំផន ទៅនឹងការកោះហៅសាក្សី 2-TCW-987 (ឯកសារ E364)**

១. អង្គជំនុំជម្រះបានទទួលសំណើរបស់មេធាវីការពារក្តី ខៀវ សំផន ដែលនៅក្នុងសំណើនោះ មេធាវីការពារក្តីស្នើសុំឱ្យអង្គជំនុំជម្រះកែប្រែសេចក្តីសម្រេច តាមគំនិតផ្តួចផ្តើមរបស់អង្គជំនុំជម្រះ ក្នុងការកោះហៅសាក្សី 2-TCW-987 ("សំណើ") (ឯកសារ E364 កថាខណ្ឌ ១២, ប្រតិចារឹក ថ្ងៃទី ០៣ ខែ កញ្ញា ឆ្នាំ ២០១៥ ទំព័រ ៩៩-១០៣, ១០៥-១០៦ (ភាសាអង់គ្លេស))។ សហព្រះរាជអាជ្ញាជំទាស់ទៅនឹងសំណើនេះ (ប្រតិចារឹក ថ្ងៃទី ០៣ ខែ កញ្ញា ឆ្នាំ ២០១៥ ទំព័រ ១០៣-១០៤ (ភាសាអង់គ្លេស))។ នៅថ្ងៃទី ២៤ ខែ ធ្នូ ឆ្នាំ ២០១៥ អង្គជំនុំជម្រះបានជូនដំណឹងដល់ភាគីទាំងអស់អំពីសេចក្តីសម្រេចរបស់អង្គជំនុំជម្រះក្នុងការស្តាប់សក្ខីកម្មសាក្សីរូបនេះ ក្នុងអំឡុងពេលជំនុំជម្រះលើប្រធានបទស្តីអំពីការប្រព្រឹត្តិចំពោះជនជាតិចាម (E364/1.1)។ អនុស្សរណៈនេះបង្ហាញជូននូវសំអាងហេតុចំពោះសេចក្តីសម្រេចនេះ។

២. មេធាវីការពារក្តី ខៀវ សំផន អះអាងថា សេចក្តីសម្រេចកោះហៅសាក្សី 2-TCW-987 រំលោភលើគោលការណ៍សមភាពនៃមធ្យោបាយក្នុងការតទល់ក្តី និងសិទ្ធិទទួលបានពេលវេលា និងមធ្យោបាយគ្រប់គ្រាន់របស់ជនជាប់ចោទក្នុងការត្រៀមរៀបចំការការពារខ្លួនគាត់ ដោយសារតែការយឺតយ៉ាវក្នុងការជូនដំណឹង និងអង្គហេតុដែលថា មេធាវីការពារក្តីមិនធ្លាប់បានឮពីមុនមកឡើយអំពីបុគ្គលរូបនេះ មុនពេល

ទទួលបានការជូនដំណឹងអំពីការជ្រើសរើសយករូបគាត់នោះ (ឯកសារ E364 កថាខណ្ឌ ១០, ប្រតិចារឹក ថ្ងៃទី ០៣ ខែ កញ្ញា ឆ្នាំ ២០១៥ ទំព័រ ១០០ (ភាសាអង់គ្លេស))។ ជាពិសេស មេធាវីការពារក្ដីជំទាស់ទៅនឹងអង្គហេតុដែលថា សាក្សី 2-TCW-987 មិនត្រូវបានស្នើឡើងដោយភាគីណាមួយឱ្យមកផ្តល់សក្ខីកម្មនៅក្នុងសំណុំរឿង ០០២/០២ ឬជាកម្មវត្ថុនៃសំណើរបស់សហព្រះរាជអាជ្ញា ស្របតាមវិធាន ៨៧(៤) នៃវិធានផ្ទៃក្នុងនោះឡើយ ហើយសាក្សីរូបនេះត្រូវបានស្តាប់ចម្លើយតែនៅក្នុងបរិបទនៃការស៊ើបសួរក្នុងសំណុំរឿង ០០៤ ប៉ុណ្ណោះ (ឯកសារ E364 កថាខណ្ឌ ៨-១០, ប្រតិចារឹក ថ្ងៃទី ០៣ ខែ កញ្ញា ឆ្នាំ ២០១៥ ទំព័រ ៩៩-១០១, ១០៣ (ភាសាអង់គ្លេស))។ មេធាវីការពារក្តី ខៀវ សំផន អះអាងថា ចម្លើយពីក្នុងសំណុំរឿង ០០៣ និង ០០៤ មិនគួរអនុញ្ញាតឱ្យយកមក "ពង្រីកបន្ថែម" ការជំនុំជម្រះសំណុំរឿង ០០២/០២ នាពេលបច្ចុប្បន្ននេះ ដោយគ្មានការកំណត់ ដែលការស៊ើបអង្កេតក្នុងសំណុំរឿងនេះបានបញ្ចប់ទៅហើយនោះឡើយ ពីព្រោះជនជាប់ចោទត្រូវមានសិទ្ធិចូលពិនិត្យមើលភ័ស្តុតាងទាំងមូលនោះ (ឯកសារ E364 កថាខណ្ឌ ៨-១១, ប្រតិចារឹក ថ្ងៃទី ០៣ ខែ កញ្ញា ឆ្នាំ ២០១៥ ទំព័រ ១០៦ (ភាសាអង់គ្លេស))។

៣. សហព្រះរាជអាជ្ញាឆ្លើយតបថា កំណត់ហេតុស្តាប់ចម្លើយចំនួនពីររបស់សាក្សី 2-TCW-987 មានចំនួន ១៥ ទំព័រ យ៉ាងច្រើនបំផុតជាភាសាបារាំង ដូច្នេះការពិនិត្យឡើងវិញលើកំណត់ហេតុស្តាប់ចម្លើយទាំងពីរនេះ មិនមែនជាកិច្ចការមួយដែលមិនអាចធ្វើទៅបាននោះទេ ត្រឹមថ្ងៃកំណត់ផ្តល់សក្ខីកម្មរបស់សាក្សីរូបនេះ។ ពួកគាត់អះអាងបន្ថែមទៀតថា វាជាឆន្ទានុសិទ្ធិរបស់អង្គជំនុំជម្រះសាលាដំបូងក្នុងការសម្រេចថាត្រូវស្តាប់សក្ខីកម្មសាក្សីរូបនេះ តាមគំនិតផ្តួចផ្តើមរបស់អង្គជំនុំជម្រះនោះ (ប្រតិចារឹក ថ្ងៃទី ០៣ ខែ កញ្ញា ឆ្នាំ ២០១៥ ទំព័រ ១០៣-១០៤ (ភាសាអង់គ្លេស))។

៤. អង្គជំនុំជម្រះសាលាដំបូងសូមរំលឹកថា អង្គជំនុំជម្រះមានឆន្ទានុសិទ្ធិក្នុងការសម្រេចថាតើត្រូវស្តាប់សក្ខីកម្មបុគ្គលរូបណានៅក្នុងអំឡុងពេលនៃកិច្ចដំណើរការនីតិវិធីជំនុំជម្រះទាំងនេះ ហើយអង្គជំនុំជម្រះអាចសម្រេចតាមគំនិតផ្តួចផ្តើមរបស់ខ្លួន ក្នុងការស្តាប់សក្ខីកម្មបុគ្គលណាមួយដែលអង្គជំនុំជម្រះយល់ឃើញថាមានប្រយោជន៍ដល់ការស្វែងរកការពិត (សូមមើល វិធាន ៨៤(២), ៨៧(៤), ៩១ នៃវិធានផ្ទៃក្នុង)។ អង្គ-ជំនុំជម្រះកត់សម្គាល់ថា មេធាវីការពារក្តី ខៀវ សំផន លើកឡើងជាថ្មីឡើងវិញនូវការជំទាស់ជាទូទៅរបស់ខ្លួនទៅនឹងការប្រើប្រាស់សម្ភារៈដែលបានដាក់បង្ហាញពីសំណុំរឿង ០០៣ និង ០០៤ ទៅក្នុងសំណុំរឿង ០០២/០២ (សូមមើល ឯកសារ E364 កថាខណ្ឌ ៨-១០, ឯកសារ E363) និងសូមរំលឹកថា អង្គជំនុំជម្រះបានដោះស្រាយ និងបដិសេធការជំទាស់នេះរួចហើយនៅក្នុងឯកសារ E363/3។ អង្គជំនុំជម្រះសាលាដំបូងយល់ឃើញថា ការជំទាស់របស់មេធាវីការពារក្តី ខៀវ សំផន ចំពោះការស្តាប់សក្ខីកម្មសាក្សី 2-TCW-987 ផ្អែកជាចម្បងទៅលើសិទ្ធិរបស់ជនជាប់ចោទក្នុងការទទួលបានពេលវេលា និងមធ្យោបាយគ្រប់គ្រាន់ក្នុងការ

ត្រៀមរៀបចំការការពារខ្លួនគាត់ និងសិទ្ធិស្មើភាពគ្នាក្នុងការពិនិត្យមើលព័ត៌មាន (ឯកសារ E364 កថាខណ្ឌ ១០)។ អង្គជំនុំជម្រះទទួលស្គាល់ថា ភាគីមិនបានទទួលការជូនដំណឹងជាមុនយូរឡើយ នៅពេលដែលអង្គជំនុំជម្រះកំណត់កាលបរិច្ឆេទពីដំបូងក្នុងការយកសាក្សី 2-TCW-987 មកជំនួសសាក្សី 2-TCW-955។ ការធ្វើបែបនេះ គឺដោយសារតែអង្គជំនុំជម្រះទទួលបានព័ត៌មានថ្មីទាក់ទងនឹងសុខភាពរបស់សាក្សី 2-TCW-955 ក្នុងរយៈពេលខ្លី មុនពេលដែលគាត់ត្រូវបានកំណត់កាលបរិច្ឆេទមកផ្តល់សក្ខីកម្មនោះ។ ទោះបីជាយ៉ាងណាក៏ដោយ អង្គជំនុំជម្រះបានដកសាក្សី 2-TCW-987 នេះ ចេញជាបណ្តោះអាសន្នពីតារាងកំណត់កាលបរិច្ឆេទសវនាការ នៅខណៈពេលដែលអង្គជំនុំជម្រះពិចារណាលើការជំទាស់របស់មេធាវីការពារក្តី ខៀវ សំផន (*សូមមើល* ឯកសារ E364/1.2)។

៥. សាក្សីរូបនេះ បានផ្តល់សក្ខីកម្មនៅថ្ងៃទី ១១ ខែ មករា ឆ្នាំ ២០១៦ គឺរយៈពេលជាងបួនខែ បន្ទាប់ពីភាគីទទួលបានការជូនដំណឹងពីដំបូងថា គាត់ត្រូវបានជ្រើសរើសឱ្យមកផ្តល់សក្ខីកម្មក្នុងនាមជាសាក្សីនៅក្នុងសំណុំរឿង ០០២/០២។ លើសពីនេះទៀត អង្គជំនុំជម្រះកត់សម្គាល់ថា កំណត់ហេតុស្តាប់ចម្លើយពីក្នុងសំណុំរឿង ០០៤ របស់សាក្សី 2-TCW-987 បានដាក់បង្ហាញទៅដល់មេធាវីការពារក្តី ប្រហែលជានៅថ្ងៃទី ២០ ខែ មីនា ឆ្នាំ ២០១៥ (ឯកសារ E319/19.3.93, E319/19.3.219)។ ដោយពិចារណាទៅលើពេលវេលាបន្ថែម ដែលបានផ្តល់ទៅឱ្យមេធាវីការពារក្តីក្នុងការត្រៀមរៀបចំសម្រាប់ការមកផ្តល់សក្ខីកម្មរបស់សាក្សីរូបនេះ អង្គជំនុំជម្រះយល់ឃើញថា មេធាវីការពារក្តីទទួលបានពេលវេលា និងមធ្យោបាយគ្រប់គ្រាន់សម្រាប់ការត្រៀមរៀបចំ។ អាស្រ័យហេតុនេះ សេចក្តីសម្រេចរបស់អង្គជំនុំជម្រះក្នុងការស្តាប់សក្ខីកម្មសាក្សី 2-TCW-987 តាមគំនិតផ្តួចផ្តើមរបស់អង្គជំនុំជម្រះ មិនរំលោភទៅលើសិទ្ធិរបស់ជនជាប់ចោទឡើយ។ ដូច្នេះ សំណើសុំនេះត្រូវបដិសេធចោល។

៦. ចុងក្រោយ អង្គជំនុំជម្រះកត់សម្គាល់ថា កំណត់ហេតុស្តាប់ចម្លើយរបស់សាក្សីរូបនេះ គឺជាកម្មវត្ថុនៃសំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិសុំឱ្យទទួលយកកំណត់ហេតុស្តាប់ចម្លើយ អនុលោមតាមវិធាន ៨៧(៤) នៃវិធានផ្ទៃក្នុង (ឯកសារ E319/32) ដែលបានធ្វើឡើងនៅថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០១៥ ហើយអង្គជំនុំជម្រះបានយល់ព្រមតាមសំណើសុំនេះ នៅថ្ងៃទី ១៨ ខែ កុម្ភៈ ឆ្នាំ ២០១៦ (ឯកសារ E319/32/1)។

៧. នេះគឺជាចម្លើយតបជាផ្លូវការរបស់អង្គជំនុំជម្រះសាលាដំបូងទៅនឹងឯកសារ E364។